ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៧០ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើស្តង់ដារទាក់ទងនឹងសវនកម្ម និង ស្តង់ដារការអះអាងអន្តរជាតិនៃកម្ពុជា

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៨/អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- យោងស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការត្រួតពិនិត្យគុណភាពរបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា
- បានឃើញរបាយការណ៍ប្រជុំរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១០
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

# ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យប្រើនូវស្តង់ដារទាក់ទងនឹងសវនកម្ម និង ស្តង់ដារការអះអាងអន្តរជាតិនៃកម្ពុជា ដែលអនុវត្តទាំងស្រុងតាមរាល់ស្តង់ដារទាក់ទងនឹងសវនកម្ម និងការអះអាងអន្តរជាតិ ចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារសវនកម្មនិងស្តង់ដារនៃការអះអាងអន្តរជាតិ *របស់សហព័ន្ធគណនេយ្យករអន្តរជាតិ* ដោយរាប់បញ្ចូលទាំងការធ្វើបច្ចុប្បន្នកម្មដែលអាចកើតមានឡើងនៅគ្រប់កាលៈទេសៈ ចំពោះស្តង់ដារអន្តរជាតិនីមួយៗនោះផង។

**ប្រការ ២.-**

ស្តង់ដារទាក់ទងនឹងសវនកម្ម និង ស្តង់ដារការអះអាងអន្តរជាតិនៃកម្ពុជា រួមមាន :

១- ស្តង់ដារអន្តរជាតិស្តីពីប្រព័ន្ធគ្រប់គ្រងគុណភាពសវនកម្ម នៃកម្ពុជា

២- ស្តង់ដារអន្តរជាតិស្តីពីសវនកម្ម នៃកម្ពុជា

៣- ស្តង់ដារអន្តរជាតិស្តីពីការពិនិត្យឡើងវិញលើរបាយការណ៍ហិរញ្ញវត្ថុ នៃកម្ពុជា

៤- ស្តង់ដារអន្តរជាតិស្តីពីការអះអាង នៃកម្ពុជា

៥- ស្តង់ដារអន្តរជាតិនៃកម្ពុជាស្តីពីសេវាកម្មផ្សេងៗ រួមទាំងសេចក្តីណែនាំសម្រាប់ការអនុវត្តស្តង់ដារខាងលើ។

**ប្រការ ៣.-**

ក្រុមប្រឹក្សាជាតិគណនេយ្យ ហៅកាត់ថា **ក.ជ.គ** និងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ហៅកាត់ថា **វ.គ.ស.ក** មានភារកិច្ចនិងការទទួលខុសត្រូវរួមគ្នាក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តតាមប្រកាសនេះ និងរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

**ក.ជ.គ** និង **វ.គ.ស.ក** មានភារកិច្ចចាត់ចែងការបកប្រែសម្រួលពីភាសាបរទេសមកជាភាសាជាតិ នូវស្តង់ដារអន្តរជាតិនីមួយៗនោះ។

**ប្រការ ៤.-**

ការមិនអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវចាត់ទុកជាការល្មើសមាត្រា ១៨ និង ១៩ នៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២។

**ប្រការ ៥.-**

ប្រកាសលេខ ៧៩៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣ ស្តីពីការដាក់ឱ្យប្រើស្តង់ដារសវនកម្ម **(ស.ត.ក)** ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា នាយកក្រុមហ៊ុនសវនកម្ម និងប្រធានអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តតាមតួនាទីរៀងៗខ្លួននូវប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**គាត ឈន់**

**<u>ចម្លងជូន:</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មការមូលបត្រកម្ពុជា

  **" ដើម្បីគោរពជូនជ្រាប "**
- ដូចប្រការ ៦

  **"ដើម្បីអនុវត្ត"**
- ឯកសារ-កាលប្បវត្តិ